**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០២៩.៥ នណ/សសរ

ថ្ងៃព្រហស្បតិ៍ ១៤រោចខែ ចេត្រ ឆ្នាំវក ព.ស. ២៥៥៩

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ ឧសភា គ.ស. ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសចំពោះកិច្ចដើម្បីសហការអនុវត្តសាលដីកា តុលាការកំពូលលេខ ១៥៧ "ខ" ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## <u>សម្រេច</u>

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសចំពោះកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសហការអនុវត្តសាលដីកាតុលាការកំពូលលេខ ១៥៧ "ខ" ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **សៀក ចណ្ណា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. | លោក **ឈី ណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិក |

អាសយដ្ឋាន : ឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

| | | |
|---|---|---|
| ៣. លោក **ទេព ស្រុង** | ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល | សមាជិក |
| ៤. លោក **ឈុំម សោភ័ណ** | ប្រធាននាយកដ្ឋានបច្ចេកទេស | សមាជិក |
| ៥. លោក **ម៉ែន សុគា** | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ | សមាជិក |
| ៦. លោក **គួច វុគនៈ** | អនុប្រធានការិយាល័យសិក្សា នៃនាយកដ្ឋានបច្ចេកទេស | សមាជិក |
| ៧. លោក **គង់ ជាសិរីឫទ្ធិ** | ប្រធានការិយាល័យបច្ចេកទេសសុរិយោដី និងភូមិសាស្ត្រ នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ | សមាជិក |
| ៨. លោក **លឹម តី** | ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌច្បារអំពៅ | សមាជិក |

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ច ÷

- ស្រាវជ្រាវឯកសារពាក់ព័ន្ធបន្ថែម
- ប្រជុំពិភាក្សាអំពីរបៀបរបបអនុវត្ត
- ចុះដល់ទីតាំងដីទំនាស់ ធ្វើការវាស់វែង ដោយសហការជាមួយអាជ្ញាសាលា និងអាជ្ញាធរមានសមត្ថកិច្ច ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ជា សុផារ៉ា**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ
- ដូចប្រការ ៣
- ឯកសារ កាលប្បវត្តិ